មើលវីដេអូ ភាគទី ២៥

# ២- ទោមនស្សសហគតំ បដិឃសម្បយុត្តំ សសង្ខារិកំ

ស្កេនដើម្បីមើលមេរៀន

San Sochea Official

មានចេតសិកប្រកបជាមួយ ២២ ប្រភេទគឺ៖

-អញ្ញសមានាចេតសិក ១២ (វៀរបីតិ)

-មោចតុក្កៈ ៤

-ទោចតុក្កៈ ៤

-ថីទុកៈ ២



# សរុបទោសមូលចិត្ត ២ ដួង

១- ទោមនស្សសហគតំ បដិឃសម្បយុត្តំ អសង្ខារិកំ

២- ទោមនស្សសហគតំ បដិឃសម្បយុត្តំ សសង្ខារិកំ

**ពាក្យគន្លឹះងាយចាំ ក្នុងទោសមូលចិត្ត ២ ដួង**



## ហេតុនាំឱ្យកើតទោសមូលចិត្តមាន ៤ យ៉ាង គឺ ៖

១- ទោសជ្ឈាសយតា ភាពជាអ្នកចងនូវសេចក្តីក្រោធទុក។

២- អគម្ភីរបកតិតា ជាអ្នកមិនមានភាពល្អិតសុខុម ជាប្រក្រតី។

៣- អប្បសុតតា ជាអ្នកស្តាប់ព្រះសទ្ធម្មតិចតួច។

៤- អនិដ្ឋារម្មណសមាយោគោ ជួបប្រសព្វនឹងអនិដ្ឋារម្មណ៍។

# ធម៌ជាហេតុលះទោសមូលចិត្តមាន ៦ យ៉ាងគឺ ៖

| | |
|---|---|
| ១- មេត្តានិមិត្តស្ស ឧគ្គហោ | ការរៀនយកនូវមេត្តានិមិត្ត។ |
| ២- មេត្តាភាវនានុយោគោ | ការបំពេញព្យាយាមក្នុងមេត្តាភាវនា។ |
| ៣-កម្មស្សកតាបច្ចវេក្ខណា | ពិចារណាឃើញថា សត្វមានកម្មជារបស់ខ្លួន។ |
| ៤- បដិសង្ខានពហុលីកតា | ភាពជាអ្នកពិចារណាច្រើន។ |
| ៥- កល្យាណមិត្តតា | ជាអ្នកមានកល្យាណមិត្ត។ |
| ៦- សប្បាយកថា | មានកថាជាទីសប្បាយ។ |

# ការចែកទោសមូលចិត្ត ២ ដួងដោយន័យផ្សេងៗ

១- ដោយជាតិ ជាអកុសលជាតិ។

២- ដោយភូមិ កើតក្នុងកាមាវចរភូមិ ១១ ជាន់។

៣- ដោយវេទនា ជាទោមនស្សវេទនាទាំង ២ ដួង។

៤- ដោយហេតុ ជានហេតុ និង ជាទ្វិហេតុកចិត្ត។

៥- ដោយសង្ខារ ជាអសង្ខារិក ១ សសង្ខារិក ១។

៦- ដោយសម្បយុត្ត ជាបដិឃសម្បយុត្តទាំង ២ ដួង។

៧- ដោយសោភណៈ ជាអសោភណចិត្ត។
៨- ដោយឈាន ជាអកុសលឈាន។
៩- ដោយលោកិយៈ ជាលោកិយចិត្ត។
១០- ដោយកិច្ច ធ្វើជវនកិច្ច។
១១- ដោយអារម្មណ៍ ដឹងអារម្មណ៍ទាំង ៦។
១២- ដោយទ្វារ កើតតាមទ្វារទាំង ៦។
១៣- ដោយវត្ថុ អាស្រ័យតែហទយវត្ថុប៉ុណ្ណោះ។
១៤- ដោយវិញ្ញាណធាតុ ជាមនោវិញ្ញាណធាតុ។